ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន

លេខ: ០៨៦ ប្រ.ក ......ប.ស្ថ

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០០៧

# ប្រកាស

## ស្តីពីការបង្កើតការិយាល័យនីតិកម្ម និងវិវាទ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២.នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤.១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០១ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុរបស់ ក្រសួងបរិស្ថាន ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ ស្តីពីការតម្លើងអធិការដ្ឋានរបស់ក្រសួងបរិស្ថានទៅជាអគ្គាធិការដ្ឋាន
- យោងប្រកាសលេខ៤៣ ប្រក.បស្ថ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០០១ ស្តីការរៀបចំ និងការប្រព្រឹត្តិទៅ របស់នាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ ។

## សំរេច

ប្រការ១ : ត្រូវបានបង្កើតការិយាល័យនីតិកម្ម និងវិវាទ ចំណុះនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ ។

ប្រការ២: ការិយាល័យនីតិកម្ម និងវិវាទ របស់នាយកដ្ឋានការពារ និង អភិរក្សធម្មជាតិ មានតួនាទីភារកិច្ច :

- រៀបចំ កសាង ពិនិត្យ កែសំរួលសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋាន គតិយុត្តនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- រៀបចំសំណុំរឿង និងដោះស្រាយបទល្មើស លើធនធានធម្មជាតិ និងបរិស្ថាន ក្នុងតំបន់ការពារធម្មជាតិតាមនីតិវិធីច្បាប់
- តាមដាន និងជម្រុញ ការអនុវត្តអោយបានត្រឹមត្រូវតាមច្បាប់ នូវសេចក្តីសំរេចអំពីការពិន័យ និង ការលក់វត្ថុ សំភារៈ ឧបករណ៍ផ្សេងទៀត ដែលរឹបអូសបាន នៅក្នុងតំបន់ការពារធម្មជាតិ ដោយអនុវត្តស្របតាមនីតិវិធីច្បាប់ ។/.

- ចុះអប់រំណែនាំ ដល់មន្ត្រីគ្រប់គ្រងតំបន់ការពារធម្មជាតិទាំងអស់ អំពីច្បាប់ និងនិតិវិធី ដោះស្រាយបទល្មើស លើធនធានធម្មជាតិ និងបរិស្ថាន ក្នុងតំបន់ការពារធម្មជាតិ
- ត្រួតពិនិត្យបញ្ជីសំណុំរឿងបទល្មើស លើធនធានធម្មជាតិ និងបរិស្ថាន ក្នុងតំបន់ការពារធម្មជាតិ
- ធ្វើកំណត់ហេតុចោទប្រកាន់ជនល្មើស លើធនធានធម្មជាតិ និងបរិស្ថាន នៅក្នុងតំបន់ការពារធម្មជាតិ
- សរុបលទ្ធផល ដោះស្រាយបទល្មើស លើធនធានធម្មជាតិ និងបរិស្ថាន ក្នុងតំបន់ការពារធម្មជាតិ
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់អោយ ។

ប្រការ៣ : ការិយាល័យនីតិកម្ម និងវិវាទ របស់នាយកដ្ឋានការពារ និង អភិរក្សធម្មជាតិ មានប្រធាន០១រូប និង អនុប្រធានជាជំនួយការងារតាមការចាំបាច់ ។

ប្រការ៤ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ នាយកខុទ្ទកាល័យទេសរដ្ឋមន្ត្រី ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ និង អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ម៉ារ៉េត

**<u>ចំលងជូន</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  (ដើម្បីជូនជ្រាប)
- ដូចប្រការ ៤ " ដើម្បីអនុវត្តន៍ "
- ឯកសារ-កាលប្បវត្តិ